00417968

D97/14/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 12 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Try

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

នៅចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 22 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Try

---

**សាធារណៈ**

# សេចក្តីសម្រេចស្តីពីសំណើរបស់សហមេធាវីសុំឲ្យពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហកម្មវត្ថុឧក្រិដ្ឋកម្មរួម

---

**<u>សហព្រះរាជអាជ្ញា៖</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

**<u>សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ហុង គឹមសួន

ឡោ ជុនធី

នី ចាន់ឌី

**<u>ជនត្រូវចោទ៖</u>**

អៀង សារី

**<u>សហមេធាវីរបស់ជនត្រូវចោទ៖</u>**

អាង ឧត្តម

Michael G.KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

គង់ ពិសី

យ៉ុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

ស៊ិន សូវន

Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BEAUDOIN
Marie GUIRAUD
Lyma NGUYEN

**<u>ដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង៖</u>**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើសុំពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថា ជាសហកម្មឧក្រិដ្ឋកម្មរួម" ដែលសហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ("សំណើ[១]") អនុលោមតាមវិធាន៣៩(៤)(ក) និង៧៥(៣) នៃវិធានផ្ទៃក្នុង ។

១. កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថា ជាសហកម្មឧក្រិដ្ឋកម្មរួម ("ដីកា[២]")។ ដីកាត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ។

២. កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ។

៣. កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់សំណើសុំពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍។ នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយនឹងសំណើនោះបង្ហាញថា សហព្រះរាជអាជ្ញាពុំជំទាស់ទៅនឹងសំណើនេះទេ។ កាលពីថ្ងៃទី១៨ ខែធ្នូ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនក៏ពុំបានជំទាស់ទៅនឹងសំណើនេះដែរ។

៤. តាមរយៈសំណើរបស់ខ្លួន សហមេធាវីការពារក្តីរបស់ជនត្រូវចោទ ស្នើសុំពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍រហូតដល់ថ្ងៃទី២២ ខែមករា ឆ្នាំ២០១០។

---

[១] សំណើរបស់សហមេធាវីសុំឲ្យពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ ("សំណើ") D97/14/1។

[២] ដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ("ដីកា") D97/13។

អង្គបុរេជំនុំជម្រះ
* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណើរបស់សហមេធាវីការពារក្តីមានហេតុផលដូចខាងក្រោម៖ ១) បញ្ហាដែលនឹងត្រូវលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ មានភាពស្មុគស្មាញ ២) អំឡុងពេលមុនកាលបរិច្ឆេទផុតកំណត់មានថ្ងៃឈប់សម្រាកអន្តរជាតិចំនួន២ថ្ងៃ ដែលពេលនោះមន្ត្រីបុគ្គលិក និងអ្នកបកប្រែ នឹងពុំមានវត្តមានពេញលេញ។

៦. អនុលោមតាមវិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះអាចពន្យារពេលវេលាកំណត់តាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ។

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាជាផលប្រយោជន៍របស់ជនត្រូវចោទ ដែលត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំខ្លួន។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សំណើនេះត្រូវបានដាក់នៅមុនពេលផុតកំណត់នៃពេលវេលាកំណត់។

៨. អង្គបុរេជំនុំជម្រះពេញចិត្តចំពោះហេតុផលនៃការស្នើសុំនេះ និងកត់សម្គាល់ឃើញពុំមានការជំទាស់ណាមួយឡើយ ពីសហព្រះរាជអាជ្ញា ឬសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច÷**

**ទទួលយក** សំណើសុំពន្យារពេលនៃការដាក់បណ្តឹងឧទ្ធរណ៍។

**បង្គាប់**ឱ្យសហមេធាវីការពារក្តីរបស់ជនត្រូវចោទ ត្រូវដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ឱ្យបានត្រឹមម៉ោង**១២ថ្ងៃត្រង់ ថ្ងៃទី២២ ខែមករា ឆ្នាំ**២០១០ ជាកំហិត។

ភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

**ប្រាក់ គឹមសាន**